# វិសាលភាពសំណុំរឿង០០២នឹងត្រូវកំណត់ជាក់លាក់នាពេលដ៏ខ្លីខាងមុខ

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣

លឹម ជ័យរ័ត្ន
អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម
មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចលុបចោលដីកាបំបែកនីតិវិធីក្នុងសំណុំរឿង០០២របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កន្លងទៅ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការរយៈពេលបីថ្ងៃ នៅថ្ងៃទី១៨ និងថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ជុំវិញវិសាលភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និងបច្ច័យដែលកើតចេញពីសេចក្តីសម្រេចលុបចោលដីកាបំបែកនីតិវិធីនេះ ។

ភាគីទាំងអស់ត្រូវបានស្នើឲ្យលើកឡើងនូវសំណើជាក់លាក់ និងឆ្លើយតបនឹងសំណួរមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យមានការបញ្ជាក់ច្បាស់លាស់ ក្រោយពេលមានការលុបចោលដីកាបំបែកនីតិវិធីសំណុំរឿង០០២ ។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុពេញលេញទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២នាពេលខាងមុខដ៏ខ្លី ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីទៅមុខឲ្យបានឆាប់រហ័ស ស្របពេលស្ថានភាពសុខភាពរបស់ជនជាប់ចោទកំពុងធ្លាក់ចុះដុនដាបខ្លាំង ហើយតុលាការកំពុងជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុដែលពុំអាចបើកប្រាក់ខែជូនបុគ្គលិកខាងភាគីជាតិ ។

តាមរយៈសវនាការដែលអង្គជំនុំជម្រះសាលាដំបូងរៀបចំដើម្បីកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យមានការដាក់បញ្ចូលបន្ថែមនូវអង្គហេតុទាក់ទងនឹងការសម្លាប់មនុស្សនៅមន្ទីរស-២១ ឬគុកទួលស្លែងទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ។ ប៉ុន្តែក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម បានស្នើឲ្យអង្គជំនុំជម្រះគួរតែជំនុំជម្រះលើសំណុំរឿង ០០២ទាំងមូលតែម្តង ។ ជាងនេះទៅទៀត ក្រុមមេធាវីការពារក្តី ខៀវ សំផន បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបំបែកកូនក្តីរបស់ខ្លួនចេញពីការជំនុំជម្រះរួមគ្នាជាមួយនឹងជនជាប់ចោទ នួន ជា និង អៀង សារី ដែលកំពុងជួបប្រទះនឹងបញ្ហាសុខភាព ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ ខៀវ សំផន គឺល្អប្រសើរ និងអាចចូលរួមស៊ើរគ្រប់សវនាការជំនុំជម្រះសេចក្តី

ហើយ ខៀវ សំផន ត្រូវការឲ្យអង្គជំនុំជម្រះជម្រះកាត់សេចក្ដីមកលើខ្លួនឲ្យបានឆាប់រហ័ស ដោយសារ រហូតមកដល់ពេលនោះ ខៀវ សំផន នៅរង់ចាំការជំនុំជម្រះសេចក្ដីលើរូបខ្លួនក្នុងពន្ធនាគារអស់រយៈពេល ជាង៥ឆ្នាំរួចមកហើយ ។

តាមរយៈសំណើសុំរបស់ភាគីទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២នាពេលនេះ កំពុងឆ្លុះបញ្ចាំង ឲ្យឃើញថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកសំណើរបស់សហព្រះរាជអាជ្ញា និងដើម បណ្ដឹងរដ្ឋប្បវេណី ឬសំណើរបស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុម ក៏លទ្ធភាពក្នុងការចេញ សាលក្រមឲ្យបានឆាប់រហ័សទំនងជានឹងត្រូវពន្យាពេល ។ ការពន្យាពេលក្នុងការចេញសាលក្រម គឺជាការ សាកល្បងនឹងភាពប្រថុយប្រថានដែលមានហានិភ័យខ្ពស់ ដោយសារជនជាប់ចោទមានវ័យចាស់ជរាខ្លាំង និងកំពុងជួបប្រទះបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលទំនងជាមិនអាចមានជីវិតរហូតដល់ពេលមានសាលក្រមស្ថាពរ ។

ទោះបីយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ ថាតើគួរត្រូវជំនុំជម្រះ លើសំណុំរឿង០០២ទាំងមូល ឬត្រូវបន្តបំបែកកិច្ចដំណើរការនីតិវិធីឲ្យទៅជាផ្នែកតូច ដូចដែលខ្លួនធ្លាប់បាន ធ្វើ ។ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសម្រេចដែលមានសំអាងហេតុពេញលេញទាក់ទងនឹងវិសាលភាព នៃសំណុំរឿង០០២នេះ នៅពេលដ៏ខ្លីខាងមុខ ។ ក្រោយពីការចេញសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះអាច នឹងចាប់ផ្ដើមសវនាការឡើងវិញភ្លាមៗ ដោយអាចស្ដាប់សក្ខីកម្មសាក្សីជំនាញ ហ៊ុំលីព ស៊ិត និង អេលីហ្សាប៊ែត បេកគ័រ រួមជាមួយនឹងសាក្សី៤រូបផ្សេងទៀត ។